**ចំណាប់អារម្មណ៍របស់លោក ជួប សុខចំរើន**
**ប្រធានគណៈកម្មាធិការដឹកនាំ របស់គណៈកម្មាធិការសម្របសម្រួល**
**សកម្មភាពសុខភាព**
**ជាតំណាងអង្គការសង្គមស៊ីវិល កំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងជា**
**នាយកប្រតិបត្តិ**
**អង្គការខាណា ថ្លែងក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ ធ្នូ ២០១៩**

- សូមគោរពអង្គពិធីទាំងមូល
- សូមគោរព ឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត
- សូមគោរព ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- សូមគោរព លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅ កម្ពុជា

សូមគោរព លោកជំទាវ ឯកឧត្តម លោក លោកស្រី ឯកអគ្គរាជទូត តំណាងអង្គទូត តំណាងដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ ទាំងអស់ជាទីគោរព។ បងប្អូនអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញជនងាយរងគ្រោះ និងក្រុមប្រឈមមុខខ្ពស់ ដែលមានវត្តមាននៅទីនេះ ជាទីស្រលាញ់រាប់អាន!

ក្នុងនាមអង្គការសង្គមស៊ីវិល ដែលបាននឹងកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាកិត្តិយស និងថ្លែងមតិ ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ក្រោមប្រធានបទ "ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍" នាថ្ងៃនេះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះផងដែរ ខ្ញុំបាទក៏សូមសម្តែងនូវមោទនភាព និងការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះគ្រប់ស្ថាប័នជាតិទាំងអស់ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ក្រោមមគ្គុទេសក៏ដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែផ្តល់ភាពងាយស្រួលអោយមានការចូលរួមជាពហុវិស័យ ដោយគិតទាំងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដែលរហូតមកទល់នឹងពេលនេះ កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ មានអាយុកាល ២៩ ឆ្នាំកន្លងមកហើយ។ ភាពបើកទូលាយ ការសហការ និងការចូលរួម បានធ្វើឱ្យកម្ពុជាយើងទទួលបានជោគជ័យជាបន្តបន្ទាប់ និងទទួលស្គាល់ជាលក្ខណៈជាតិ និងទាំងនៅលើឆាកអន្តរជាតិដែលជាមេរៀនបទពិសោធន៍អាចប្រើ

ប្រាស់បានសម្រាប់ការងារលើកកម្ពស់វិស័យសុខភាពដទៃផ្សេងទៀតរាប់ទាំងការប្រយុទ្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង ក៏ដូចជាកម្មវិធីអភិវឌ្ឍន៍ផ្សេងៗទៀត។

ជាមួយនេះផងដែរ ក្នុងនាមអង្គការសង្គមស៊ីវិលទាំងអស់ ដែលបាននឹងកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងអេដស៍ ក៏ដូចជាបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខទាំងអស់ ជាថ្មីម្តងទៀត ខ្ញុំសូមចូលរួមអបអរសាទរនូវភាពជោគជ័យរបស់កម្ពុជាដែលក្នុងខែកក្កដា ឆ្នាំ២០១៧ កន្លងទៅនេះ ទទួលបាននូវការទទួលស្គាល់ជាអន្តរជាតិ ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនតែប្រាំពីរប៉ុណ្ណោះ នៅលើពិភពលោកដែលសម្រេចបាននូវគោលដៅ ៩០ទាំងបី នៅឆ្នាំ២០២០ មុនកាលកំណត់ និងជាពិសេសសក្នុងឆ្នាំ២០១៨ និង២០១៩ បានបន្តនូវភាពជឿនលឿនក្នុងការស្វែងរកអ្នកដែលមានផ្ទុកមេរោគអេដស៍ ដែលមិនទាន់បានដឹងខ្លួននៅឡើយ ហើយជួយពួកគេឱ្យទទួលបានការធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលយកនូវការព្យាបាលនៅតាមមន្ទីរពេទ្យបង្អែកនៅទូទាំងប្រទេស។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី លោកជំទាវ លោក លោកស្រីជាទីគោរព!**

ក្នុងគោលដៅកម្ពុជាឆ្ពោះទៅសម្រេចបានការលុបបំបាត់ការឆ្លងមេរោគថ្មីនាឆ្នាំ២០២៥នៃគោលដៅ ៩៥% ៩៥% និង៩៥% នោះខ្ញុំមានជំនឿយ៉ាងមុតមាំថា យើងពិតជាអាចធ្វើបានប្រសិនបើកម្ពុជាយើង បន្តនូវការខិតខំបន្ថែមទៀតក្នុងការលុបបំបាត់នូវគម្លាតរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវាដោយក្នុងនោះរួមមានការលុបបំបាត់នូវការប្រមាថម៉ាក់ងាយ និងការរើសអើងនៅកន្លែងផ្តល់សេវា និងការពង្រឹងនូវគុណភាពនៃការផ្តល់សេវា។

បន្ថែមលើសពីនេះទៀត ការផ្តល់ជំនួយបច្ចេកទេស និងការជួយគាំទ្រផ្នែកហិរញ្ញវត្ថុបន្តសម្រាប់អង្គការសង្គមស៊ីវិល និងបណ្តាញនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងបណ្តាញនៃក្រុមប្រឈមមុខខ្ពស់គឺនឹងជួយឱ្យពួកគេអាចស្វែងរក និងជួយដល់អ្នកមិនទាន់ធ្វើរោគវិនិច្ឆ័យ បានធ្វើតេស្តឈាម និងទទួលបានការព្យាបាលទាន់ពេលវេលា និងជួយឱ្យពួកគេស្ថិតក្នុងការព្យាបាលជាប់លាប់រហូតដល់បន្ទុកមេរោគអេដស៍មានការថយចុះ ឬរកមិនឃើញ។

បន្ថែមលើសនេះទៀត ការផ្តល់នូវជម្រើសផ្សេងៗ រួមមានការទទួលបានសេវាធ្វើតេស្តឈាម រកមេរោគអេដស៍ដោយខ្លួនឯង ដែលក្រសួងសុខាភិបាលតាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) បាននិងកំពុងអនុញ្ញាតឱ្យមានការចាប់ផ្តើមនាឆ្នាំ២០១៩នេះ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកបម្លែងភេទ និងក្រុមស្ត្រីដែលបម្រើការនៅតាមគ្រឹះស្ថាន កំសាន្តសប្បាយ អាចជួយឱ្យអ្នកដែលស្ថិតក្នុងស្ថានភាពរស់នៅជាមួយមេរោគអេដស៍ដោយមិនដឹងខ្លួន ឬជាក្រុមចុងក្រោយសម្រាប់ជួយឱ្យយើងទទួលបានជោគជ័យក្នុងការលុបបំបាត់ការចម្លងថ្មីមានជម្រើសកាន់តែច្រើន និងជួយពួកគេទទួលបានការធ្វើតេស្តឈាមកាន់តែមានភាពងាយស្រួល គ្មានការភ័យព្រួយអំពីសុវត្ថិភាពព័ត៌មានបុគ្គលរបស់ពួកគេ និងជួយឱ្យពួកគេកាន់តែមានភាពម្ចាស់ការ និងមានភាពទទួលខុសត្រូវ ក្នុងការ

ថែទាំសុខភាពរបស់ពួកគេ។ បន្ថែមលើសនេះទៀត ការជួយឱ្យក្រុមអ្នកប្រឈមមុខខ្ពស់ និងមានឥរិយាបថសកម្មក្នុងការរួមភេទមានដៃគូច្រើន និងប្រើប្រាស់ថ្នាំញៀន ទទួលបានឱសថបង្ការជាមុន (PreP) ដែលបាននឹងកំពុងចាប់ផ្តើមក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងសុខាភិបាល រួមជាមួយនឹងដៃគូ គឺជាវិធីសាស្ត្របង្ការមួយដ៏មានប្រសិទ្ធភាព ក្នុងការទប់ស្កាត់ការចម្លងថ្មីក្នុងចំណោមក្រុមអ្នកប្រឈមមុខខ្ពស់ ជាពិសេសគឺក្រុមបុរសរួមភេទជាមួយបុរសស្ថិតក្នុងវ័យក្មេង។

កន្លងមក អង្គការសង្គមស៊ីវិល និងបណ្តាញនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខផ្សេង ទៀត បានចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាល អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និអាជ្ញាធរ ដែនដីនៅគ្រប់កម្រិត ដើម្បីធ្វើអោយការឆ្លើយតបចំពោះមេរោគអេដស៍មានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ ការខិតខំទាំងនេះរួមមានការផ្តល់សេវាអប់រំផ្សព្វផ្សាយ បង្កើនចំណេះដឹងអំពីការបង្ការមេរោគអេដស៍ ការផ្តល់សារអប់រំ និងចែកចាយស្រោមអនាម័យ ការផ្តល់សេវាប្រឹក្សានិងធ្វើតេស្តឈាមហ័សនៅតាមសហគមន៍ ការបញ្ជូន ការផ្តល់ការថែទាំ និងការតាមដានលើការព្យាបាលដើម្បីអោយក្រុមគោលដៅជាក្រុមប្រឈមមុខខ្ពស់ និងក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ទទួលបានសេវាសុខភាព និងសេវាពាក់ព័ន្ធនឹង មេរោគអេដស៍ និងជំងឺអេដស៍តាមតម្រូវការរបស់ពួកគេ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី លោកជំទាវ លោក លោកស្រីជាទីគោរព!**

ទោះបីជាកម្ពុជាយើង ក្រោមការដឹកនាំដោយផ្ទាល់អំពីឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ទទួលបានជោគជ័យយ៉ាងធំធេងលើការត្រួតពិនិត្យ និងការគ្រប់គ្រងការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ក៏ដោយ ក៏ប៉ុន្តែបើយោងទៅតាមទិន្នន័យ និងរបាយការណ៍របស់ក្រសួងសុខាភិបាល ក៏យើងនៅឃើញថា ជារៀងរាល់ថ្ងៃនៅតែមានមនុស្សចំនួន២នាក់បានឆ្លងមេរោគអេដស៍ និងមានអ្នកជំងឺអេដស៍ប្រហែលជា៦នាក់បានស្លាប់ដោយសារជំងឺនេះ ឬដោយសារជំងឺឱកាសនិយម។

**នេះគឺដោយសារបញ្ហា និងឧបសគ្គមួយចំនួន ដែលខ្ញុំបាទ សូមលើកជាយោបល់ និងសូមស្នើ ដូចខាងក្រោម៖**

1. ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ នៅតែជាបញ្ហាស្មុគស្មាញដែលទាមទារអោយគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ បន្តការសហការ និងធ្វើការរួមគ្នាកាន់តែជិតស្និទ្ធដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះ។ បើតាមតួលេខក្នុងឆ្នាំ២០១៩ គិតមកដល់ត្រឹមខែតុលា លើការផ្តល់សេវារបស់អង្គការសង្គមស៊ីវិលក្នុងរាជធានី/ខេត្ត នៅទូទាំងប្រទេសសម្រាប់ក្រុមប្រឈមមុខខ្ពស់ រួមមានបុរសស្រឡាញ់បុរស ស្ត្រីបម្រើការនៅតាមសេវាកំសាន្តសប្បាយ និងក្រុមអ្នកបំប្លែងភេទ ទទួលបានការអប់រំអំពីមេរោគអេដស៍គឺមានចំនួនសរុបរហូតដល់ ៦៩០១៨ នាក់ ដែលក្នុងនោះប្រមាណ ៧៥%ទទួលបានការធ្វើតេស្តឈាមរកមេរោគអេដស៍និងបានដឹងអំពីស្ថានភាពរបស់ខ្លួន តែដោយឡែកប្រមាណ

២៥%ទៀត មិនទាន់ដឹងអំពីស្ថានភាពរបស់ខ្លួននិងបានបន្តចម្លងទៅអ្នកដទៃ ឬទទួលការចម្លងពីគេ។លទ្ធផលដែលមានលក្ខណៈល្អប្រសើរបែបនេះ បើធៀបជាមួយនឹងបណ្តាឆ្នាំមុនៗ គឺដោយសារការអនុវត្តនូវវិធីសាស្រ្តថ្មីតាមបែបមិត្តស្វែងរកមិត្ត (PDI+) និងការដាក់អោយការធ្វើតេស្តឈាមដោយខ្លួនឯងនិងការចាប់ផ្តើមនូវការផ្តល់ថ្នាំបង្ការជាមុន។ ក្នុងចំណោមអ្នកដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍ ដែលមានចំនួន ៥១៦៧៥ នាក់ គឺមានករណីរកឃើញថ្មីប្រមាណជាង ៥២១ ករណី ត្រូវបានជួយនិងបញ្ជូនទៅរកសេវាព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ (ARV) ហើយដែលភាគច្រើននៃពួកគេ គឺជាក្រុមបុរសរួមភេទជាមួយបុរសវ័យក្មេងមានអាយុក្រោម ៣០ ឆ្នាំ។

ជាងនេះទៅទៀតនោះ យើងក៏បានដឹងផងដែរថា តាមលទ្ធផលនិងរបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) នៃក្រសួងសុខាភិ បាល ការរកឃើញករណីថ្មី នៃអ្នករស់នៅជាមួយមេរោគអេដស៍ គឺជាង៧០ភាគរយគឺមិនស្ថិតនៅក្នុងចំណោមប្រជាជនប្រឈមមុខខ្ពស់ទាំងអស់នោះទេ តែពួកគេគឺក្រុមមនុស្សដែលស្ថិតក្នុងចំណោមក្រុមប្រជាជនទូទៅនៅក្នុងសហគមន៍ និងជាក្រុមមនុស្សដែលយើងមិនបានដឹងអំពីអត្តសញ្ញាណ និងប្រវត្តិពីមុនរបស់ពួកគេ។ ដូច្នេះដើម្បីជួយអោយអ្នករស់នៅជាមួយមេរោគអេដស៍ ប្រមាណ៩០ឬ៩៥ភាគរយបានដឹងអំពីស្ថានភាពរបស់គេនោះការផ្សព្វផ្សាយ និងការលើកទឹកចិត្តអោយទទួលយកការអប់រំការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍បានគ្រប់ៗគ្នា ក្នុងចំណោមក្រុមអ្នកប្រឈមមុខខ្ពស់នៃការចម្លងមេរោគអេដស៍ និងក្រុមមិនបានដឹងអំពីអត្តសញ្ញាណ និងប្រវត្តិពីមុនគឺជារឿងសំខាន់ និងជាចាំបាច់បំផុត។ ក្រៅអំពីការងារអប់រំបង្ការមេរោគអេដស៍ និងជំងឺអេដស៍ អង្គការសង្គមស៊ីវិល រួមជាមួយបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ នៅបានផ្តល់ ការថែទាំ និងគាំទ្រដល់អ្នករស់នៅមេរោគអេដស៍ ចំនួន ៦១១៥២ នាក់ គិតត្រឹមខែ វិច្ឆិកា ឆ្នាំ២០១៩។ បន្ថែមលើសនេះ មានស្រ្តីមានផ្ទៃពោះដែលរស់នៅជាមួយមេរោគអេដស៍ចំនួន ៣៨៤ នាក់ ទទួលបានការថែទាំសម្រាប់ការបង្ការការចម្លងពីម្តាយទៅកូន។

2. បើពិនិត្យមើល ទៅលើថវិកាសំរាប់ការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដែលធ្លាប់ទទួលបានពី អង្គការម្ចាស់ជំនួយគឺមានការធ្លាក់ចុះជាបណ្តើរៗ ចាប់តាំងពីចុងឆ្នាំ ២០១៥ ដែលជាហេតុធ្វើ ឱ្យចំនួនអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើការប្រយុទ្ធទប់ស្កាត់នឹងជំងឺអេដស៍មានការធ្លាក់ចុះជាគំហុកដោយសារមិនមានថវិកាគ្រប់គ្រាន់ធ្វើការជាមួយនឹងបញ្ហានេះ។ ជាងនេះទៅទៀត អង្គការសង្គមស៊ីវិលប្រហែលជា៧០ភាគរយបានបិទទ្វារ និងស្ទើរតែមិនមានកម្មវិធីតទៅទៀត ហើយការងារប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍បច្ចុប្បន្ននេះ គឺផ្តោតតែទៅលើតំបន់ដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ជាហេតុធ្វើអោយតំបន់មួយចំនួន មិនមានកម្មវិធីអេដស៍ និងក្រុមគោលដៅមួយចំនួនមិនស្ថិតនៅក្រោមការគ្រប់ដណ្តប់នៃការផ្តល់សេវា។ បច្ចុប្បន្ននេះអង្គការសង្គមស៊ីវិលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរុករកក្រុមប្រឈមដើម្បីផ្តល់សេវាបង្ការ ថែទាំ ក៏ដូចជាការ

ពង្រឹងសមត្ថភាពដល់តំណាងក្រុមប្រឈមនៅតាមសហគមន៍ដើម្បី ឱ្យពួកគេចូលរួមក្នុងការជំរុញក្រុមគោលដៅអោយមកទទួលសេវា និងចូលរួមផងដែរក្នុងការពង្រឹងពីគុណភាពនៃការផ្តល់សេវាទៅដល់ក្រុមគេផងដែរ។ ហេតុដូច្នេះខ្ញុំបាទសូមស្នើរាជរដ្ឋាភិបាល មេត្តាពិចារណាក្នុងការចាប់ផ្តើមផ្តល់ថវិកាពីរាជរដ្ឋាភិបាលក្នុងការគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងការបន្តការរុករក និងថែទាំដល់ក្រុមជនរងគ្រោះទាំងនោះដើម្បីធានាថាមិនមានអ្នកណាម្នាក់ត្រូវបានគេទុកចោល មិនទទួលបានការអប់រំ ការថែទាំ និងការព្យាបាល ដើម្បីលើកកម្ពស់គុណភាពជីវិត។

3. គប្បីលើកកម្ពស់នូវការចូលរួមទាំងអស់គ្នាក្នុងការផ្តល់ការថែទាំប្រកដដោយគុណភាព រាប់ទាំងការផ្តល់នូវតួនាទីរបស់អ្នករស់នៅជាមួយមេរោគអេដស៍ លើការផ្តល់សេវាព្យាបាល ដល់សហគមន៍ពួកគេ រួមមានទាំងការផ្តល់ឱសថនិងការតាមដាននូវការវិវត្តន៍នូវបន្ទុកមេរោគអេដស៍។

4. ធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការសម្រួលសម្រួលជាមួយគ្រឹះស្ថានកំសាន្តសប្បាយដែលគ្រប់គ្រងដោយជនបរទេស ដែលអាចជួយអោយក្រុមអប់រំ អាចមានលទ្ធភាពចូលទៅតំបន់នោះក្នុងការធ្វើការអប់រំ។

5. សូមស្នើរាជរដ្ឋាភិបាល តាមរយៈឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី មេត្តាជួយទទួលអ្នកផ្ទុកមេរោគអេដស៍នៅតាមសហគមន៍ ដើម្បីអោយពួកគេមានឱកាសធ្វើជាអ្នកស្ម័គ្រចិត្តក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍របស់ពួកគេនៅតាមសហគមន៍ និងទទួលបានប្រាក់ឧបត្ថម្ភគាំទ្រ និងសូមស្នើរាជរដ្ឋាភិបាល មេត្តាបន្តជួយពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ដើម្បីឱ្យពួកគេមានភាពជាអ្នកដឹកនាំ និងមានសមត្ថភាពក្នុងការដាក់បញ្ចូលកម្មវិធីអេដស៍នៅក្នុងផែនការវិនិយោគ និងអភិវឌ្ឍន៍ឃុំ/សង្កាត់។

6. ការអន្តរាគមន៍បង្ការគួរផ្តោតយកចិត្តនិងពង្រីកបន្ថែម តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឌីជីថល ដល់ក្រុមយុវវ័យដែលងាយនឹងប្រឈមមុខខ្ពស់ក្នុងការឆ្លងមេរោគអេដស៍។

7. ខ្ញុំសូមស្នើដល់អង្គការម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ទាំងអស់ មេត្តាបន្តជួយអង្គការសង្គមស៊ីវិលសម្រាប់បណ្តាឆ្នាំចុងក្រោយនេះ ដើម្បីអោយអង្គការសង្គមស៊ីវិល មានការបណ្តុះបណ្តាល និងការកសាងសមត្ថភាព សម្រាប់ធ្វើការផ្ទេរសកម្មភាពរបស់ខ្លួន ដល់អាជ្ញាធរពាក់ព័ន្ធ រួមទាំងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងទៀតក្នុងការឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធិភាព និងមាននិរន្តរភាព។

8. ជាងនេះទៅទៀត ក្នុងនាមអង្គការសង្គមស៊ីវិល ខ្ញុំក៏សូមស្នើឱ្យមាននូវការត្រូវពិនិត្យមើលវិញផងដែរលើច្បាប់ត្រួតពិនិត្យ និងគ្រប់គ្រងជំងឺអេដស៍ និងច្បាប់ ក៏ដូចជាគោលនយោបាយផ្សេងទៀត ដើម្បី

ជានាថាច្បាប់ និងគោលនយោបាយទាំងនោះ មិនមែនជាឧបសគ្គរារាំងទៅដល់ការអនុវត្តន៍ការអប់រំ បង្ការ និងការថែទាំព្យាបាល ទៅដល់អ្នកដែលកំពុងត្រូវការសេវាទាំងនោះ។

ជាទីបញ្ចប់ និងជាទីថ្មីម្តងទៀត ក្នុងនាមអង្គការសង្គមស៊ីវិល និងតាមរយៈ **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្រ្តី** ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាសេសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានីហ៊ុន សែន ដែលតែងតែបានយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដែលធ្វើឱ្យប្រទេសកម្ពុជាយើងក្លាយជាប្រទេសមួយជោគជ័យលើការងារនេះទាំងនៅក្នុងតំបន់ និងទាំងនៅលើសាកលលោក។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **ឯកឧត្តមទេសរដ្ឋមន្រ្តី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងថ្នាក់ដឹកនាំទាំងអស់ដែលបានបង្កភាពងាយស្រួល ការដឹកនាំល្អ និងផ្តល់ការគាំទ្រនូវការចូលរួមរបស់សហគមន៍ និងអង្គការសង្គមស៊ីវិល ក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។ សូមថ្លែងអំណរគុណឯកឧត្តមរដ្ឋមន្រ្តី ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អាជ្ញាធរសុខាភិបាល និងអាជ្ញាធរមូលដ្ឋាននៅគ្រប់ជាន់ថ្នាក់ សម្រាប់ការជួយជ្រោមជ្រែង និងការសហការដ៏រលូន ដែលធ្វើឱ្យសហគមន៍ និងអង្គការសង្គមស៊ីវិល ដំណើរការកម្មវិធីរបស់ខ្លួនប្រកបដោយជោគជ័យ។ ជាមួយនឹងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គការម្ចាស់ជំនួយ រួមមាន USAID, GFATM មូលនិធិ ៥ភាគរយរបស់ប្រទេសបារាំង (The 5% French Initiative) និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត សម្រាប់ការជួយគាំទ្រនានា ដែលការជួយនេះបានជួយសង្រ្គោះ នូវជីវិតអ្នករស់នៅជាមួយ មេរោគអេដស៍រាប់រយពាន់នាក់បន្តរស់រានត្ត និងកសាងជីវភាពរស់នៅជាប្រក្រតីឡើងវិញនៅក្នុងសហគមន៍។

សូមគោរពជូនពរ **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្រ្តី** **ឯកឧត្តមទេសរដ្ឋមន្រ្តី ឯកឧត្តមរដ្ឋមន្រ្តី** លោកជំទាវ ឯកឧត្តម លោក លោកស្រីទាំងអស់ជួបប្រទះនឹងពុទ្ធពរទាំងឡាយប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ!*